ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ:..........................

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងមហាផ្ទៃ

នៅក្នុងកម្មវិធីផ្សាយរបស់វិទ្យុអាស៊ីសេរី កាលពីព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ដែលជាវិទ្យុមានភាពលម្អៀង បានធ្វើបទសម្ភាសន៍មួយជាមួយលោក Phil Robertson នាយករងទទួលបន្ទុកកិច្ចការតំបន់អាស៊ីរបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ដែលក្នុងបទសម្ភាសន៍នោះ បុគ្គល Phil Robertson បានចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាប់ មកលើក្រសួងមហាផ្ទៃថា "កំពុងយាយីមកលើគណបក្សសង្គ្រោះជាតិជុំវិញបញ្ហាលក្ខន្តិកៈរបស់គណបក្សនេះ"។

ក្រសួងមហាផ្ទៃ សូមធ្វើការបដិសេធយ៉ាងដាច់អហង្ការរាល់ការលើកឡើងដ៏ឆ្គួតលីលារបស់បុគ្គល Phil Robertson ដែលជ្រកក្រោមផ្លាកអង្គការឃ្លាំមើលសិទ្ធិមនុស្សអន្តរជាតិ ជានិច្ចកាលតែងតែមួលបង្កាច់និងបង្ខូចអរិយភាពមកលើរាជរដ្ឋាភិបាលកម្ពុជាដែលជារាជរដ្ឋាភិបាលស្របច្បាប់ កើតចេញពីឆន្ទៈរបស់ប្រជាពលរដ្ឋកម្ពុជា ស្របតាមរដ្ឋធម្មនុញ្ញ និងស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ក្រសួងមហាផ្ទៃ ចាត់ទុកការលើកឡើងដ៏ឆ្គួតលីលានេះ មិនត្រឹមតែជាការបំផ្លើស មួលបង្កាច់ ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែការលើកឡើងនេះ គឺជាការប្រមាថ មាក់ងាយយ៉ាងធ្ងន់ធ្ងរមកលើកម្ពុជាដែលជារដ្ឋមានអធិបតេយ្យភាព និងឯករាជ្យភាពយ៉ាងពេញលេញ ហើយមានចេតនាញុះញង់ ប៉ុនប៉ង យាយីដល់សន្តិភាព ស្ថិរភាពនយោបាយ និងដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។

ក្រសួងមហាផ្ទៃ មានកិត្តិយសសូមធ្វើការគូសបញ្ជាក់ជូនសាធារណមតិជាតិ និងអន្តរជាតិឱ្យបានជ្រាបថា ក្រសួងមហាផ្ទៃបាននឹងកំពុងអនុវត្តយ៉ាងពេញលេញនូវតួនាទី ភារកិច្ចរបស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ និងលិខិតបទដ្ឋាននានាជាធរមាននៅកម្ពុជា ដើម្បីលើកកម្ពស់ដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋនៅកម្ពុជា។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ បាននឹងកំពុងប្រព្រឹត្តទៅដោយរលូនស្របតាមច្បាប់បោះឆ្នោត បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោត ព្រមទាំងប្រតិទិននៃការបោះឆ្នោតដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយមានគណបក្សនយោបាយចំនួន១២ បានចុះបញ្ជីចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតនេះ ក្នុងនោះរួមទាំងគណបក្សសង្គ្រោះជាតិផងដែរ។ ក្រសួងមហាផ្ទៃក៏ដូចក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តកិច្ចការនានា ស្របតាមច្បាប់បោះឆ្នោត បទបញ្ជានិងនីតិវិធីសម្រាប់ការបោះឆ្នោត សំដៅធានាឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤នេះ ប្រព្រឹត្តទៅប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាពល្អ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧